ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៥៦ សសរ.

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពគណៈកម្មការក្រុមប្រឹក្សាវិន័យរបស់ក្រសួង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងសេចក្តីសម្រេចលេខ ០៥៧ ជនស.សសរ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការក្រុមប្រឹក្សាវិន័យរបស់ក្រសួង
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.**_

កែសម្រួលសមាសភាពគណៈកម្មការក្រុមប្រឹក្សាវិន័យរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **ខិម សំអ៊ែល** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

៣.ឯកឧត្តម **សេង ឡូត** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អនុប្រធាន
៤. ឯកឧត្តម **ម៉ែន ច័ន្ទសុខមេមរា** អគ្គាធិការនៃអគ្គាធិការដ្ឋាន សមាជិក
៥. លោក **កុសល សុពិនត្ន** ប្រធាននាយកដ្ឋានបុគ្គលិក សមាជិកអចិន្ត្រៃយ៍
៦. លោក **យួន សុជាតិ** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក
៧. លោក **អេ ម៉ិនធឿន** ប្រធាននាយកដ្ឋាននីតិកម្ម សមាជិក
៨. ប្រធាននាយកដ្ឋានឬប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្តពាក់ព័ន្ធ សមាជិក
៩. មន្ត្រីនាយកដ្ឋាន ឬមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្តពាក់ព័ន្ធ ០១រូប ដែលបំពេញការងារក្នុងអង្គភាពជាមួយគ្នានឹងអ្នករាជការជាប់ចោទ និងមានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា។ សមាជិក

**ប្រការ ២._**

គណៈកម្មការក្រុមប្រឹក្សាវិន័យមានភារកិច្ច ៖

- អនុវត្តឱ្យបានត្រឹមត្រូវតាមមាត្រាទាំងឡាយដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងអំពីវិន័យ
- អនុវត្តនីតិវិធីទៅតាមអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានជាធរមាន
- ធ្វើការសន្និដ្ឋានឱ្យបានសត្យានុម័តលើកំហុសឆ្គងរបស់មន្ត្រី ដែលត្រូវបានចោទប្រកាន់មុននឹងផ្ញើជូនក្រសួងពិនិត្យ សម្រេច និងដាក់ទណ្ឌកម្ម។

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ